# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តមឯកអគ្គរដ្ឋទូត នៃប្រទេសហ្វីលីពីនប្រចាំកម្ពុជា ដែលទើបចប់អណត្តិ



នៅទីស្តីការក្រសួង ព្រឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប ឯកឧត្តម **Noe A.Wong** ឯកអគ្គរដ្ឋទូត នៃប្រទេសហ្វីលីពីនប្រចាំកម្ពុជា ដើម្បីសម្តែងគួរសម និងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមត្រូវបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ។

ឯកឧត្តម **Noe A.Wong** ឯកអគ្គរដ្ឋទូត នៃប្រទេសហ្វីលីពីនប្រចាំកម្ពុជា ដែលទើបចប់អណត្តិ បានបង្ហាញនូវមនោសញ្ចេតនាជ្រាលជ្រៅចំពោះការបំពេញបេសកកម្មការទូតរយៈពេល០៦ ឆ្នាំនៅកម្ពុជា ក្នុងការជម្រុញទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា–ហ្វីលីពីន កាន់តែមានភាពប្រសើរឡើង ជាពិសេសលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ។ ភាពជោគជ័យនៃបេសកកម្មការទូតនេះ គឺសម្រេចបានដោយកិច្ចសហការយ៉ាងល្អប្រសើរ ពីគ្រប់ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ។ ក្នុងនោះ ឯកឧត្តម ឯកអគ្គរដ្ឋទូតក៏បានរំលឹកពីទំនាក់ទំនងដ៏ល្អជាមួយ ឯកឧត្តម ចម ប្រសិទ្ធ ដែលឯកឧត្តមជាអតីតទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងកិច្ចសហការពង្រឹងផ្នែកដោះដូរពាណិជ្ជកម្ម ។ ជាពិសេស គឺសម្រេចកិច្ចព្រមព្រៀងការនាំចូលអង្ករពីកម្ពុជាទៅកាន់ប្រទេសហ្វីលីពីន និងផលិតផលពីប្រទេសហ្វីលីពីនចូលមកទីផ្សារកម្ពុជា រួមជាមួយកិច្ចសហប្រតិបត្តិការលើវិស័យធុរៈកិច្ច និងវិនិយោគផ្សេងៗទៀត ។ ទាក់ទង និងវិស័យទេសចរណ៍ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះវិស័យនេះ ជាពិសេសគឺការបង្កើតឱ្យមានជើងហោះហើរដោយត្រង់ពីទីក្រុង ម៉ានីល មកខេត្តសៀមរាប ។ ទាក់ទងបញ្ហានេះ ឯកឧត្តម ឯកអគ្គរដ្ឋទូត ក៏បានបង្ហាញនូវបំណងចង់ឱ្យមានការបន្ថែមជើងហោះហើរ ពីហ្វីលីពីនមកកម្ពុជាផងដែរ ។

ដោយប្រទេសកម្ពុជា ជាប្រទេសកសិកម្ម ឯកឧត្តម ឯកអគ្គរដ្ឋទូត ក៏បានលើកឡើងពីគុណភាពដីកសិកម្ម នៃប្រទេសហ្វីលីពីន និងស្នើឱ្យកម្ពុជាពិនិត្យលទ្ធភាពប្រើប្រាស់ដីនេះ ដើម្បីជួយបង្កើនទិន្នផលដំណាំដាំដុះរបស់ខ្លួន ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ ចំពោះបេសកកម្មការទូតរបស់ឯកឧត្តម **Noe A.Wong** នៅកម្ពុជា ដែលបានបំពេញកិច្ចការសម្រេចលទ្ធផលវិជ្ជមានជាច្រើន ទាំងវិស័យការទូត និងសេដ្ឋកិច្ច ។ ទាក់ទងវិស័យទេសចរណ៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានឯកភាព និងផ្តល់សារៈសំខាន់ទៅលើការបន្ថែមជើងហោះដោយត្រង់ ពីព្រោះជាវិស័យដែលមានសក្តានុពលនៅកម្ពុជា ។ ចំពោះការប្រើប្រាស់ជីកសិកម្មដែលផលិតនៅប្រទេសហ្វីលីពីន ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអំពាវនាវឱ្យអ្នកដែលមានបំណងវិនិយោគធ្វើការពិភាក្សាជាមួយជំនាញក្រសួងកសិកម្ម ហើយឯកឧត្តមគាំទ្រផងដែរ ចំពោះការបង្កើតរោងចក្រផលិតជីនៅកម្ពុជា។

ជាចុងក្រោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបង្ហាញនូវជំនឿ និងបានបញ្ជាក់ថាៈតាមរយៈការបំពេញបេសកកម្មការទូត រយៈពេល០៦ ឆ្នាំ នៅកម្ពុជា ឯកឧត្តមឯកអគ្គរដ្ឋទូត ពិតជាបានយល់ច្បាស់ពីស្ថានភាពពិតនៅកម្ពុជា ហើយពេលទទួលភារកិច្ចថ្មី ឯកឧត្តមនឹងជួយផ្សព្វផ្សាយបន្ថែមទៀត ពីលក្ខណៈអំណោយផល និងសក្តានុពល នៃប្រទេសកម្ពុជា ដែលកំពុងទទួលបានសុខសន្តិភាព មានស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាការទាញទំនុកចិត្តសម្រាប់អ្នកវិនិយោគទុន ក៏ដូចជាភ្ញៀវទេសចរណ៍អន្តរជាតិមកកម្ពុជា។

